# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែឧសភា ឆ្នាំ២០១៤

នៅក្នុងខែឧសភា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ០១លើក

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តសន្តិសុខារាម ក្របៅ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានចុះហត្ថលេខាលើលិខិតចំនួន ៤១លិខិត និងព្រះរាជក្រឹត្យចំនួន ៤១

-ពិនិត្យ ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ជូនគណៈកម្មការជំនាញព្រឹទ្ធសភាចំនួន ០៤ច្បាប់

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារនៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ ចំនួន០២ច្បាប់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន ១១លិខិត។

**១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ ព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន ០២លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក

-អញ្ជើញជាកិត្តិយសជូនព្រះរាជដំណើរព្រះករុណា ព្រះមហាក្សត្រ ព្រះអង្គយាងទៅបំពេញព្រះរាជកិច្ច នៅសាធារណរដ្ឋបារាំង

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធី ច្រត់ព្រះនង្គ័ល និងទស្សនាពិព័រណ៍ផលិតផលក្នុងស្រុក ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅក្រុងតាខ្មៅ ខេត្តកណ្តាល



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

025

-អញ្ជើញទទួលដំណើរសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា អញ្ជើញវិលត្រឡប់មកពីពិនិត្យសុខភាព នៅប្រទេសសិង្ហបូរី

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី១៥១ទិវាពិភពលោកកាក បាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា

+អញ្ជើញចុះការងារមូលដ្ឋានៈ

-អញ្ជើញចុះស្វែងយល់ពីការអនុវត្តន៍គោលនយោបាយស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅតាមបណ្តាខេត្ត ក្នុងភូមិភាគទី៧ ចំនួន០៤លើក

-អញ្ជើញចូលរួមដោះស្រាយកង្វល់ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាសង្កាត់មួយចំនួន ក្នុងរាជធានីភ្នំពេញ

-អញ្ជើញដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋ ក្នុងសង្កាត់ជ្រោយចង្វារជុំវិញការរៀបចំស្ថានីយ៍បូមទឹកចេញពីភូមិដ្ឋាននារដូវវស្សា

-ជ្រាបជាព័ត៌មាន ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន ១៧៩លិខិត ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បានៈ**

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីទទួលព្រះរាជដំណើររបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងត្រឡប់មកពីបំពេញព្រះរាជកិច្ចនៅប្រទេសបារាំង

-អញ្ជើញជាអធិបតីក្នុងវេទិកាភូមិភាគទី៥ស្តីពី "លើកកម្ពស់សមធម៌យេនឌ័រ ដើម្បីប្រសិទ្ធភាពដឹកនាំ"

-អញ្ជើញចូលរួមជាកិត្តិយសខួបលើកទី១៥១ឆ្នាំ ទិវាពិភពលោកកាកបាទក្រហមអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៤

-អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយជូនសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទាំង១១ស្រុក-ក្រុង ក្នុងខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ៦៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក ដើម្បីៈ**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៥ ទៅគណៈកម្មការជំនាញ ៖

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ នៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ

២.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

៣.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីគយ

៤.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងលើការសុំចូលរួមជាភាគីហត្ថលេខី របស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ

៥.ពិនិត្យសំណើររបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស៊ីធីលុមអេសអេ សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងសហប្រតិបត្តិការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈ នៅរាជធានីភ្នំពេញ ។

៦.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣

៧.កំណត់កាលបរិច្ឆេទរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែឧសភានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម ៖

**៣.១ មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ ។

**៣.២ មុខងារតំណាង**

-ទទួលពាក្យបណ្តឹងចំនួន ០៤ករណី និងបានបញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបានចំនួន ០២ករណី និងទទួលបានលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងចំនួន ០១បណ្តឹង

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពីការកែសម្រួលលើគម្រោងចំណាយ

សម្រាប់រៀបចំវេទិកា

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យឆ្លងរបាយការណ៍លទ្ធផលស្តីពីការពិគ្រោះយោបល់របស់ព្រឹទ្ធសភា ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តឧត្តរមានជ័យ

-ប្រជុំក្រុមសភាកម្ពុជា-អាយភីយូ ដើម្បីរៀបចំអនុសាសន៍ដាក់ក្នុងសេចក្តីសម្រេច ស្តីពី "ច្បាប់អន្តរជាតិទាក់ទងទៅនឹងអធិបតេយ្យជាតិ ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃទៀត និងសិទ្ធិមនុស្ស ដែលយកទៅអនុម័តក្នុងមហាសន្និបាតលើកទី ១៣២ របស់អាយភីយូ"

-ប្រជុំជាមួយលោកបណ្ឌិត Daniel HEILMANN ទីប្រឹក្សាជាន់ខ្ពស់អាល្លឺម៉ង់ថ្មីអមព្រឹទ្ធសភា អំពីការផ្តល់សេវាកម្ម កិច្ចសហការ និងស្វែងយល់អំពីតម្រូវការរបស់គណៈកម្មការ

-សិក្ខាសាលាស្តីពី "ការរៀបចំនិងការប្រព្រឹត្តិទៅ នៃសភាធ្លុះបញ្ចាំងតាមរយៈបទពិសោធន៍សភាប្រទេសវៀតណាម និងបទពិសោធន៍ប្រទេសនានា"

-ជួបពិភាក្សាការងារជាមួយលោក **ដារ៉ារិទ្ធ គឹមយាត** នាយកប្រតិបត្តិវិទ្យាស្ថានសភាកម្ពុជា (PIC)ស្តីអំពី "ការសិក្សាប្រៀបធៀបបញ្ហានានា នៃដំណើរការបោះឆ្នោតនៅប្រទេសបារាំង កូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូនេស៊ី"

-ជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **ចែម វិទ្យា** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការពាក់ព័ន្ធនឹងសំណើររបស់សហភាពអន្តរសភា (IPU)

-បទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា" ជូនដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន៧០នាក់

-បទបង្ហាញស្តីពី "ការវិនិយោគ និងសិទ្ធិមនុស្ស" ឧទ្ទេសនាមដោយលោក Stephan W.Schill ទីប្រឹក្សានៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយជម្លោះវិនិយោគ(ICSID) សាស្ត្រាចារ្យច្បាប់នៅសកលវិទ្យាល័យ Frankfurt

-ទទួលជួបគណៈប្រតិភូរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមដែលដឹកនាំដោយលោកស្រី LI THIDERN អភិបាលរងខេត្តកនទុន

-អនុញ្ញាតឲ្យអ្នកវិនិយោគមកពីប្រទេសអ៊ីស្រាអែល ជប៉ុន សាធារណរដ្ឋកូរ៉េ ចូលជួបពិភាក្សាការងារ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ១១៤លើក ដើម្បីសំណេះសំណាល ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្ត

គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អ សេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន ៤៤លើក ។

**៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **ឈិត គីមយាត** បានអញ្ជើញចូលរួមកិច្ចប្រជុំរវាងអាយប៉ា និងថ្នាក់ដឹកនាំអាស៊ាន នាជំនួបកំពូលអាស៊ានលើកទី៣២ នៅទីក្រុងណាទីថរ ប្រទេសមីយ៉ាន់ម៉ា និងកិច្ចប្រជុំ AIFOCOM លើកទី១១ ឆ្នាំ២០១៨ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

-ឯកឧត្តម **ម៉ុង ឫទ្ធី** បានអញ្ជើញទៅទស្សនកិច្ចសិក្សាស្វែងយល់ក្រុមហ៊ុនផលិតប្រេង នៅព្រះរាជាណាចក្រថៃឡង់។

-ឯកឧត្តម **ឡាវ ម៉េងឃីង** បានអមដំណើរសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមកិច្ចប្រជុំកំពូលលើកទី៤ របស់ប្រមុខរដ្ឋរដ្ឋាភិបាល នៃសន្និសីទអន្តរសកម្ម និងវិធានការកសាងទំនុកចិត្តនៅអាស៊ី នៅទីក្រុងសៀងហៃនៃសាធារណរដ្ឋប្រជាមានិតចិន ។

-សម្តេចរាជបុត្រីព្រះរៀម **បុប្ផា ទេវី** បានយាងដង្ហែរ ព្រះករុណាព្រះបាទ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាយាងបំពេញរាជកិច្ច នៅសាធារណរដ្ឋបារាំង ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន
លេខ ០៥៧ /១៦២៤/អ.ពស/ផ.ស.៤

# លិខិតដឹកនាំ

## សូមគោរពជូន

សម្តេច ចៅហ្វាវាំង ទរទៀងជ័យ អធិបតីស្រីវ្លារ ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន

| ល.រ | បរិយាយ | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា ប្រចាំខែឧសភា ឆ្នាំ២០១៤ ។ | ០១ | ដើម្បីគោរពជូនជ្រាបជាព័ត៌មាន ។ |

ភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការ**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh